ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកវគ្គសុក្រឹតការជំនាន់ទី១០ សំរាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
## ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ នៅធនាគារជាតិនៃកម្ពុជា

សូមគោរព

- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាសិក្ខាកាមទាំងអស់ ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាអតិបរិមា ដោយបានចូលរួមជាមួយលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ក្នុងពិធីបើកវគ្គសុក្រឹតការជំនាន់ទី ១០ សម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជារបស់យើង ។ វគ្គសុក្រឹតការនេះ ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ដើម្បីផ្ដល់ឱកាសឱ្យមន្ត្រីបុគ្គលិករបស់យើងដែលកំពុងបំរើការងារ ទាំងនៅទីស្នាក់ការកណ្ដាល និងនៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត-រាជធានីបានទទួលនូវការបំពាក់បំប៉ន និងការបណ្ដុះបណ្ដាលចំណេះដឹងថ្មីៗ ទាំងផ្នែកទ្រឹស្ដីនិងការអនុវត្តជាក់ស្ដែង និងបានស្វែងយល់ពីការរីកចម្រើននៃសេដ្ឋកិច្ច ជាពិសេស ការវិវឌ្ឍរីកចម្រើននៃប្រព័ន្ធធនាគារជាតិនៃកម្ពុជា ។

ខ្ញុំសូមស្វាគមន៍ចំពោះវត្តមានរបស់លោកជំទាវ ឯកឧត្តម លោក-លោកស្រី ជាមន្ត្រីឧទ្ទេសនាម ដែលបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកវគ្គសុក្រឹតការ នាពេលនេះ ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាសិក្ខាកាមទាំងអស់ ជាទីមេត្រី**

ឆ្លៀតឱកាសនេះ ខ្ញុំសូមជំរាបអំពី :

១- សភាពការណ៍រីកចម្រើនថ្មីនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជានៅក្នុងឆមាសទី១ ឆ្នាំ២០០៩

២- គោលបំណងនៃការបង្កើតវគ្គសុក្រឹតការ

៣- ការអភិវឌ្ឍធនធានមនុស្សរបស់ធនាគារជាតិនៃកម្ពុជា ។

### ១. សភាពការណ៍រីកចម្រើនថ្មីនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

នៅឆ្នាំនេះ ពិភពលោកយើងប្រឈមមុខនឹងបញ្ហាធំៗមួយចំនួន ដូចជា *១)*-ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចជុំទី២ ដែលបណ្ដាលមកពីវិបត្តិហិរញ្ញវត្ថុសកលលោក *២)*-និន្នាការឈានទៅរកការប្រែប្រួលការប្រើដុល្លារអាមេរិកធ្វើជា

ទុនបម្រុងអន្តរជាតិចំបង ៣)-ការបន្ថែមកញ្ចប់ថវិការដ្ឋដើម្បីជំរុញកំណើនសេដ្ឋកិច្ច ៤)-ការប្រែប្រួលតួនាទីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ៥)-ការប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុនិងយុទ្ធសាស្ត្រធ្វើអាជីវកម្មដោយមានកិច្ចការពារបរិស្ថាន ៦)-បាតុភូតជំងឺគ្រុនផ្តាសាយជ្រូក (Swine Flu H1N1) និង៧)-ការរើបឡើងវិញនៃថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ។ កត្តាទាំងនេះហើយដែលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចពិភពលោក ។

នៅឆមាសទី១ ឆ្នាំ២០០៩ នេះ តាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថាសេដ្ឋកិច្ចពិភពលោកនឹងធ្លាក់ចុះដល់ -១,៣% ធៀបនឹងអត្រា ៤,១% នៅឆមាសទី១ ឆ្នាំ២០០៨ ដោយអត្រាកំណើនសេដ្ឋកិច្ចអាមេរិកនឹងធ្លាក់ត្រឹមកម្រិត -២,៨% សហគមន៍អឺរ៉ុប -៤,២% ប្រទេសជប៉ុន -៦,២% ប្រទេសចិន ៦,៥% និងប្រទេសឥណ្ឌា ៤,៥% ។ ចំណែកកំណើនសេដ្ឋកិច្ចនៃក្រុមប្រទេសអាស៊ាននឹងកើនក្នុងកម្រិត 0,៦% ធៀបអត្រានឹង ៥,១% នៅឆមាសទី១ ឆ្នាំ២០០៨ ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា យើងត្រូវខិតខំសម្រេចឱ្យបានអត្រាកំណើនសេដ្ឋកិច្ច ៦% នៅឆ្នាំ២០០៩ នេះ ខណៈស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ត្រូវបានទ្រទ្រង់ដោយការថយចុះជាបន្តបន្ទាប់នៃសម្ពាធអតិផរណា និងស្ថិរភាពអត្រាប្តូរប្រាក់ ។ វិបត្តិសេដ្ឋកិច្ចបានជះឥទ្ធិពលដោយប្រយោលទៅលើវិស័យពិត (Real sector) នៃសេដ្ឋកិច្ចកម្ពុជា ដូចជា វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងវិនិយោគផ្ទាល់បរទេស ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុបបានធ្លាក់ចុះ ។

ចំពោះបញ្ហាអតិផរណា បន្ទាប់ពីអនុវត្តវិធានការជាកញ្ចប់របស់រាជរដ្ឋាភិបាលរួចមក បានថយចុះចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៨ និងបានធ្លាក់ចុះជាបន្តបន្ទាប់ ពីកម្រិតខ្ពស់បំផុត ៣៥,៦% នាខែឧសភា ឆ្នាំ២០០៨ រហូតដល់កម្រិតអវិជ្ជមាន -៤,៩% នាខែមិថុនា ឆ្នាំ២០០៩ ។ ការធ្លាក់ចុះនេះ ដោយសារតម្រូវការប្រើប្រាស់ទំនិញ នៅទូទាំងពិភពលោកបានធ្លាក់ចុះ ។ នៅឆ្នាំ២០០៩ នេះ តាមការព្យាករណ៍របស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចកម្ពុជានឹងមានកំណើនក្នុងកម្រិត ២,១% ខ្ពស់ជាងការព្យាករណ៍បែបទុទិដ្ឋិនិយមរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

## ២. គោលបំណងនៃការបង្កើតវគ្គសុក្រឹតការ

គិតត្រឹមបំណាច់ខែមិថុនា ឆ្នាំ២០០៩ នេះ មន្ត្រីបុគ្គលិករបស់យើងទូទាំងប្រទេសសរុបចំនួន ១.២២៦ នាក់ ក្នុងនោះនៅទីស្នាក់ការកណ្តាលចំនួន ៨២៦ នាក់ ប្រុសចំនួន ៤៥០ នាក់ ស្រីចំនួន ៣៧៦ នាក់ និងនៅសាខាធនាគារជាតិនៃកម្ពុជាខេត្ត-រាជធានីចំនួន ៤០០ នាក់ ប្រុសចំនួន ២២៨ នាក់ ស្រីចំនួន ១៧២ នាក់ ។ ដោយយល់ឃើញពីភាពចាំបាច់ និងសេចក្តីត្រូវការរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារ ខ្ញុំបានអនុញ្ញាតឱ្យរៀបចំវគ្គសុក្រឹតការនេះឡើងចំនួន ៩ លើកហើយ តាំងពីឆ្នាំ១៩៩៩ មក ដោយមានមន្ត្រីចូលរួមចំនួន ៦៤៥ នាក់ ក្នុងនោះមន្ត្រីនៅទីស្នាក់ការកណ្តាលចំនួន ៣៣៨ នាក់ និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-រាជធានីចំនួន ៣០៧ នាក់ បានបញ្ចប់វគ្គសុក្រឹតការនេះ ។ ដោយឡែកចំពោះ វគ្គសុក្រឹតការលើកទី១០ នេះ មានសិក្ខាកាមទាំងអស់ចំនួន ៩០នាក់ ស្រីចំនួន ៥៤ នាក់ ប្រុសចំនួន ៣៦ នាក់ ក្នុងនោះ មកពីសាខាធនាគារជាតិនៃកម្ពុជាខេត្ត- រាជធានីចំនួន ៤៦ នាក់បានមកចូលរួមផងដែរ ។

គោលដៅចំបងនៃការរៀបចំវគ្គសុក្រឹតការនេះ គឺដើម្បីបំប៉នចំណេះដឹងបន្ថែមទៀតទាំងលើផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង និងផ្តល់ឱកាសឱ្យមន្ត្រីបុគ្គលិករបស់យើងទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខាខេត្ត-រាជធានី បានពិភាក្សាផ្លាស់ប្តូរយោបល់និងបទពិសោធន៍គ្នាអំពីការងារប្រចាំថ្ងៃ និងដើម្បីផ្សារភ្ជាប់មនោសញ្ចេតនាស្និទ្ធស្នាល រួមសាមគ្គីគ្នាជាលក្ខណៈការងារក្រោមដំបូលតែមួយ និងជាពិសេស បានយល់ដឹងអំពីបេសកកម្មនិងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

តាមរយៈវគ្គសុក្រឹតការនេះ លោក លោកស្រី នាងកញ្ញា នឹងបានស្តាប់ការពន្យល់បកស្រាយរបស់គ្រូឧទ្ទេសនាមយើងអំពី ការដឹកនាំនយោបាយរូបិយវត្ថុ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈពេលវែង គោលការណ៍គណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការគ្រប់គ្រងទុនបំរុងអន្តរជាតិ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ កិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជាជាមួយនឹងអង្គការអន្តរជាតិនិងធនាគារកណ្តាលបរទេស គំនិតផ្តួចផ្តើមបង្កើតទីផ្សារទុននៅកម្ពុជា និងមេរៀនសំខាន់ៗ ផ្សេងទៀត ។ សូមលោក លោកស្រី ជាពិសេសត្រូវស្វែងយល់ឱ្យបានច្បាស់លាស់ពីតួនាទីនិងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដើម្បីយកទៅអនុវត្តការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

### ៣. ការអភិវឌ្ឍធនធានមនុស្សរបស់ធនាគារជាតិនៃកម្ពុជា

ធនធានមនុស្សគឺជាកត្តាស្នូលមួយក្នុងការកសាងប្រទេសជាតិ ។ ប្រទេសជាតិមានការអភិវឌ្ឍនិងរីកចម្រើនក៏អាស្រ័យដោយមានធនធានមនុស្សជាសំខាន់ ។ ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស គឺជាការងារអាទិភាពរបស់ធនាគារជាតិនៃកម្ពុជាដែលតែងតែយកចិត្តទុកដាក់ ដើម្បីបន្តពង្រឹងប្រព័ន្ធធនាគារអោយមានភាពរឹងមាំ និងសុខភាពល្អ ស្របតាមសភាពការណ៍វិវត្តន៍រីកចម្រើននៃសេដ្ឋកិច្ចពិភពលោក និងមានលក្ខណៈសមាហរណទៅនឹងតំបន់។

កន្លងមក ធនាគារជាតិនៃកម្ពុជាបានធ្វើការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ដោយឈរលើគោលការណ៍ អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ បន្ទាប់មកយើងបានធ្វើការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកយើងទាំងក្នុងនិងក្រៅប្រទេស តាមរយៈកិច្ចសហប្រតិបត្តិការទ្វេរភាគីនិងពហុភាគីជាមួយស្ថាប័នជាតិ-អន្តរជាតិ និងធនាគារកណ្តាលនៅក្រៅប្រទេស ។

តាមរយៈទំនាក់ទំនងទ្វេភាគីជាមួយធនាគារកណ្តាលនានា ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីបុគ្គលិករបស់ខ្លួនទៅធ្វើទស្សនកិច្ចសិក្សានៅធនាគារកណ្តាលនៃប្រទេសជាមិត្តទាំងនោះផងដែរ ។ ក្រៅពីការបណ្តុះបណ្តាលក៏រិតជំនាញបច្ចេកទេសហើយ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការបណ្តុះបណ្តាលផ្នែកគុណធម៌វិន័យការងារ ការទទួលខុសត្រូវចំពោះការងារ និងសីលធម៌ដល់មន្ត្រីបុគ្គលិកគ្រប់រូប ជាពិសេស ការបណ្តុះនូវវប្បធម៌ធនាគារកណ្តាល ។ ឈរលើស្មារតីទាំងនេះហើយ ទើបយើងបានកសាងប្រព័ន្ធធនាគារមួយពីបាតដៃទទេ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មក ឱ្យមានការអភិវឌ្ឍរីកចម្រើនដូចសព្វថ្ងៃនេះ ។

លោកជំទាវ ឯកឧត្តម លោក លោកស្រី និងសិក្ខាកាមទាំងអស់ ជាទីស្នេហា

ជាថ្មីម្តងទៀត ការរៀបចំវគ្គសុក្រឹតការនេះ មានសារៈសំខាន់ណាស់ចំពោះមន្ត្រីបុគ្គលិករបស់យើងទាំងអស់គ្នា ដូច្នេះដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីៗទាំងនេះ ទុកជាទុនដើម្បីបម្រើការងារឱ្យមានប្រសិទ្ធភាពខ្ពស់ សូមអស់លោក លោកស្រី និងក្មួយៗសិក្ខាកាមទាំងអស់ខិតខំត្រងត្រាប់ស្តាប់ការពន្យល់បកស្រាយទាំងផ្នែកទ្រឹស្តី និងបទពិសោធន៍ការងារជាក់ស្តែងពីមន្ត្រីឧទ្ទេសនាមរបស់យើង ដែលមានបទពិសោធន៍ជាយូរមកហើយ និងត្រូវខិតខំក្រេបជញ្ជក់យកចំណេះដឹងទៅប្រើប្រាស់ដើម្បីបំពេញភារកិច្ចចំពោះមុខ និងទៅអនាគតអោយមានប្រសិទ្ធភាព ។

ទន្ទឹមនឹងនេះ ក៏ត្រូវខិតខំសិក្សាស្រាវជ្រាវដោយខ្លួនឯងបន្ថែមទៀតទាំងផ្នែកជំនាញ និងទាំងផ្នែកភាសាបរទេស ដើម្បីបំពេញចំណុចខ្វះខាតរបស់យើងកាន់តែប្រសើរឡើងថែមទៀត ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងមន្ត្រីសិក្ខាកាមដែលមានវត្តមាននៅទីនេះ សូមមានប្រាជ្ញាវៀងវៃ សុខភាពបរិបូរណ៍ និងកំលាំងមាំមួន ដើម្បីរួមចំណែកពង្រឹងការងារធនាគារជាតិនៃកម្ពុជា ហើយក៏សូមអោយវគ្គសុក្រឹតការរបស់យើងលើកនេះមានដំណើរការប្រកបទៅដោយជោគជ័យ ។

ខ្ញុំសូមប្រកាសជាផ្លូវការបើកវគ្គសុក្រឹតការចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**